**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងរដ្ឋប្បវេណីលេខ: ៩៣
ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤

**សាលក្រមរដ្ឋប្បវេណី**
**លេខ: ១៧ "ដ"**
ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ **នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤** លើសំណុំរឿងរដ្ឋប្បវេណីលេខ: ៩៣ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤ ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**រវាងសហដើមចោទ៖** ឈ្មោះ [redacted] **ប៊ឹក** ភេទស្រី កើតថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៦២ កាន់អត្តសញ្ញាណប័ណ្ណលេខ: ១០០៨៨៤៣៩៥ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ និងឈ្មោះ [redacted] **យ៉ុង** ភេទប្រុស កើតថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៦៤ កាន់អត្តសញ្ញាណប័ណ្ណលេខ: ១០០៨៨៤៣៨៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

**អ្នកតំណាងដោយអាណត្តិ៖** លោកមេធាវី [redacted] អត្តលេខ: ២៨៤៥T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅក្រុមមេធាវី [redacted] មានអាសយដ្ឋាន [redacted] និងលោកមេធាវី [redacted] អត្តលេខ: ២៣៨៤T ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា នៅក្រុមមេធាវី [redacted] មានអាសយដ្ឋាននៅ [redacted] ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

**និងសហចុងចម្លើយ៖** ឈ្មោះ [redacted] **ភាព** កើតថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៤ និងឈ្មោះ [redacted] **ត័ណ្ហ** កើតថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៧៤ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

**អ្នកតំណាងដោយអាណត្តិ៖** "គ្មាន" ។

### ក. អង្គហេតុ និងចំណុចវិវាទ

**១. ខ្លឹមសារសាលក្រមដែលទាមទារដោយសហដើមចោទឱ្យតុលាការចេញ៖**

១.១. សុំរំលាយកិច្ចសន្យាបញ្ចាំចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ រវាងសហដើមចោទឈ្មោះ [redacted] ប៊ឹក និងឈ្មោះ [redacted] យ៉ុង ( [redacted] យ៉ុង) ជាមួយឈ្មោះ [redacted] ថន (ស្លាប់) និងឈ្មោះ [redacted] រ៉ែន (ស្លាប់) ជាអ្នកទទួលបញ្ចាំ ។

១.២. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] ត័ណ្ហ ប្រគល់ឱ្យនូវដីស្រែទំហំ៧០អា ដែលជាទ្រព្យធានាបញ្ចាំរវាងសហដើមចោទ និងមតកជនរបស់សហចុងចម្លើយ មានទីតាំងដីស្ថិតនៅ [redacted] ។

១.៣. បញ្ជាក់ទទួលស្គាល់ថាសហដើមចោទឈ្មោះ [redacted] ប៊ឹក និងឈ្មោះ [redacted] យ៉ុង ពិតជាម្ចាស់កម្មសិទ្ធិករលើដីស្រែទំហំ៧០អា មានទីតាំងស្ថិតនៅភូមិព្រៃសក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ។



Scanned with CamScanner

១.៤.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] ភ័ណ្ឌ សងសំណងជម្ងឺចិត្តចំនួន ២០,០០០,០០០ រៀល (ម្ភៃលានរៀល) មកឱ្យដើមចោទ ។

១.៥.បង្គាប់ឱ្យសហដើមចោទឈ្មោះ [redacted] ប៊ុក និងឈ្មោះ [redacted] យ៉ុង សងប្រាក់ត្រឡប់ទៅសហចុងចម្លើយឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] ភ័ណ្ឌ នូវប្រាក់ដើមចំនួន ១,៦០០,០០០ (មួយលានហុកសិបម៉ឺន) រៀល ។

១.៦.ប្រាក់ប្រដាប់ក្តី និងបង់ពន្ធផ្សេងៗជាបន្ទុករបស់សហចុងចម្លើយឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] ភ័ណ្ឌ ។

១.៧.សុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ន ។

## ២. ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ សហដើមចោទ បានបញ្ចាំអចលនវត្ថុមួយកន្លែង ដែលមានទីតាំងស្ថិតនៅភូមិព្រៃសក្រោម ឃុំទ្រាវ ស្រុកទ្រាំង ខេត្តតាកែវ ក្នុងតម្លៃ ១,៦០០,០០០ (មួយលានហុកសិបម៉ឺន) រៀល ទៅឱ្យសហចុងចម្លើយ ដោយបានធ្វើកិច្ចសន្យាបញ្ចាំអចលនវត្ថុលេខៈ ១០៦ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ រវាងឈ្មោះ [redacted] ប៊ុក និងប្តីឈ្មោះ [redacted] យ៉ុង និងឈ្មោះ [redacted] ថន និងប្រពន្ធឈ្មោះ [redacted] រ៉ើន ដោយពេលធ្វើកិច្ចសន្យានោះមានសាក្សីជាមេភូមិ និងលោកមេឃុំជាអ្នកបញ្ជាក់ការដឹងឮផងដែរ ក្រោយពេលធ្វើកិច្ចសន្យាបញ្ចាំរួច សហចុងចម្លើយមិនបានអនុវត្តតាមកិច្ចសន្យាបញ្ចាំនោះទេ ទើបតែអំឡុងឆ្នាំ២០២៤ សហដើមចោទបានទាមទារអនុវត្តកិច្ចសន្យាបញ្ចាំ និងសុំឱ្យសហចុងចម្លើយប្រគល់អចលនវត្ថុដែលបានបញ្ចាំនោះមកវិញ ប៉ុន្តែសហចុងចម្លើយមិនព្រមប្រគល់អចលនវត្ថុដែលបានបញ្ចាំនោះមកវិញឡើយ ទើបសហដើមចោទបានដាក់ពាក្យបណ្តឹងមកតុលាការតែម្តង ។

## ៣. អង្គហេតុដែលអះអាងដោយសហដើមចោទ

**អ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា:** ខ្លួនសុំរក្សាការទាមទារ ដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤, ពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ និងសេចក្តីថ្លែងការណ៍ដូចនៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ នៅដដែល និងសូមធ្វើសេចក្តីថ្លែងការណ៍បន្ថែមដូចខាងក្រោម៖

១.នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ ដើមចោទឈ្មោះ [redacted] ប៊ុក និងឈ្មោះ [redacted] យ៉ុង ([redacted] យ៉ុង) បានបង្កើតកិច្ចសន្យាបញ្ចាំលេខៈ ១០៦ ជាមួយឈ្មោះ [redacted] ថន (ស្លាប់) និងឈ្មោះ [redacted] រ៉ើន (ស្លាប់) ដើម្បីធានាបំណុលប្រាក់ដើមចំនួន ៦០០,០០០ រៀល សរសេរជាអក្សរ (ប្រាំមួយសែនរៀលគត់) ដើម្បីយកប្រាក់សងសមាគមន៍ក្នុងភូមិ និងជាប្រាក់ធ្វើសោហ៊ុយចំណាកស្រុកទៅធ្វើការប្រទេសថៃ នូវដីស្រែទំហំ៧០អា មានព្រំប្រទល់ខាងកើតទល់នឹងឈ្មោះ [redacted] ថន, ខាងលិចទល់នឹងឈ្មោះ [redacted] ហ៊ិន, ខាងជើងទល់នឹងឈ្មោះ [redacted] សារី និងខាងត្បូងទល់នឹងឈ្មោះ [redacted] សៀង ស្ថិតនៅភូមិ [redacted] ដោយចំហថ្ងៃទូទាត់សងប្រាក់បញ្ចាំនៅផ្ទះលោកអតីតមេភូមិព្រៃសក្រោម ហើយដើមចោទក៏បានចាកចេញទៅធ្វើការនៅឯប្រទេសថៃ ។ នៅក្នុងឆ្នាំ២០០៩ ដើមចោទក៏ត្រលប់មកកម្ពុជាវិញ ក្រោយស៊ីឈ្នួលរកប្រាក់បានចំនួន ២ម៉ឺន បាត ឬប្រហាក់ប្រហែល ២លានរៀល ក៏មកសុំបង់ប្រាក់រំលស់ដីស្រែ ពីឈ្មោះ [redacted] ថន (ស្លាប់) និងឈ្មោះ [redacted] រ៉ើន (ស្លាប់) ប៉ុន្តែក្នុងកិច្ចសន្យាបញ្ចាំស្រាប់តែចែងថាទំហំប្រាក់ដើមបញ្ចាំចំនួនរហូតដល់ ១,៦០០,០០០ រៀល សរសេរជាអក្សរ (មួយលានប្រាំមួយសែនរៀលគត់) ព្រមទាំងមានកំណត់ចែងថាគ្មានប្រាក់សងក្នុងរយៈពេល ០៤ ខែ ភាគីដើមចោទយល់ព្រមប្រគល់ដីផ្តាច់ចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ដល់ត្រឹមថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥វិញ ។

២.នៅអំឡុងពេលប្រើប្រាស់ប្រាក់ សហកូនបំណុលជាដើមចោទឈ្មោះ [redacted] ប៊ុក និងឈ្មោះ [redacted] យ៉ុង ([redacted] យ៉ុង) បានប្រគល់សិទ្ធប្រើប្រាស់ និងអាស្រ័យផលលើដីស្រែនេះទៅឱ្យឈ្មោះ [redacted] ថន (ស្លាប់) និងឈ្មោះ [redacted] រ៉ើន (ស្លាប់) ជាថ្នូរការប្រាក់ នៃការបញ្ចាំ ហើយរហូតមកដល់ឆ្នាំ២០០៩ សហដើមចោទឈ្មោះ [redacted] ប៊ុក និងឈ្មោះ [redacted] យ៉ុង ([redacted] យ៉ុង) បានត្រលប់មកពីធ្វើការប្រទេសថៃ ក៏សុំទូទាត់សងប្រាក់ដើម្បីលោះយកដីស្រែទំហំ ៧០អា មកវិញ តែឈ្មោះ [redacted] ថន (ស្លាប់) និងឈ្មោះ [redacted] រ៉ើន (ស្លាប់) មិនព្រមប្រគល់ដីឱ្យវិញទេ ហើយបានបញ្ជាក់ថាបើព្រមឱ្យប្រគល់ដីវិញ លុះត្រាតែដើមចោទប្រគល់ប្រាក់រំលស់ដីស្មើទៅនឹងតម្លៃមាសមួយតម្លឹងទើបឈ្មោះ [redacted] ថន (ស្លាប់) និងឈ្មោះ [redacted] រ៉ើន (ស្លាប់) ព្រមទទួលប្រាក់សងកាលនៅរស់មិនទាន់ទទួលមរណភាព ហើយក៏មានការតវ៉ាលើប្រាក់បញ្ចាំពីចំនួន ៦០០,០០



Scanned with CamScanner

(ប្រាំមួយសែនរៀលគត់) ឡើងដល់ចំនួន **១,៦០០,០០០** (មួយលានប្រាំមួយសែនរៀលគត់) ផងដែរ ។ នៅពេលនេះ ដើមចោទក៏បានស្ម័គ្រចិត្តទទួលប្រាក់បញ្ចាំចំនួន **១,៦០០,០០០** (មួយលានប្រាំមួយសែនរៀលគត់) ដោយដើមចោទសុំទូទាត់សងចំនួន **២,០០០,០០០** រៀល នៅឆ្នាំ២០០៩ តែឈ្មោះ [redacted] **រ៉ែន** មិនព្រមទទួលយកពីសហដើមចោទទេ រហូតបន្តមានវិវាទជាច្រើនលើកមកដល់បច្ចុប្បន្ននេះ ។

៣.អំឡុងពេលមានវិវាទចាប់តាំងពីឆ្នាំ២០០៩ មកដល់សព្វថ្ងៃនេះ ដើមចោទបានទាមទារដីស្រែទំហំ **៧០អា** នេះ តាមរយៈការស្នើសុំចរចារផ្ទាល់ជាច្រើនសារ រហូតមានការប្តឹងទៅអាជ្ញាធរភូមិឃុំ ហើយអាជ្ញាធរភូមិឃុំក៏បានចុះទៅសម្របសម្រួលដោះស្រាយជាញឹកញាប់ជាមួយសហចុងចម្លើយ និងបានធ្វើកំណត់ហេតុលើកចុងក្រោយនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ រវាងសហដើមចោទ និងទាយាទឈ្មោះ [redacted] **ភាព** និងឈ្មោះ [redacted] **ភ័ណ្ឌ** របស់ឈ្មោះ [redacted] **ថន** (ស្លាប់) និងឈ្មោះ [redacted] **រ៉ែន** (**ស្លាប់**) នៅពេលនេះឈ្មោះ [redacted] **រ៉ែន** (**ស្លាប់**) បានប្តឹងទៅគណៈកម្មការសុរិយោដីភូមិបាលស្រុកទ្រាំង បានឃើញពាក្យបណ្តឹងអ្នកទទួលក៏ច្រានចោលការទាមទាររបស់សហចុងចម្លើយពីសហដើមចោទផងដែរ ហើយសហដើមចោទក៏សម្រេច ប្តឹងទាមទារដីមានអត្តសញ្ញាណខាងលើរហូតមកដល់ពេលនេះ ។

ដូច្នេះទើបសហដើមចោទឈ្មោះ [redacted] **ប៊ុក** និងឈ្មោះ [redacted] **យ៉ុង**([redacted] **យ៉ុង**) កើតទុក្ខមិនសុខចិត្តនឹងគ្រួសារសហចុងចម្លើយ ក៏សុំប្តឹងមកសាលាដំបូងខេត្តតាកែវ ដើម្បីរំលាយកិច្ចសន្យាបញ្ចាំ និងសុំបង្គាប់ឱ្យភាគីសហចុងចម្លើយឈ្មោះ [redacted] **ភាព** និងឈ្មោះ [redacted] **ភ័ណ្ឌ** ជាទាយាទរបស់មតកជនឈ្មោះ [redacted] **ថន** (**ស្លាប់**) និងឈ្មោះ [redacted] **រ៉ែន** (**ស្លាប់**) ប្រគល់ដីស្រែទំហំ **៧០អា** ព្រមទាំងសំណងជម្ងឺចិត្តចំនួន **២០,០០០,០០០** (**ម្ភៃលាន**) រៀល ក្នុងការខាតបង់ពេលវេលាជាច្រើនឆ្នាំលើការទាមទារ តាមចំណុច(១),(២),(៣),(៤),(៥),(៦) និង(៧) មកឱ្យភាគីដើមចោទជាកូនក្តីរបស់ខ្លួន ។

សេចក្តីដូចបានរៀបរាប់ជូនខាងលើ កិច្ចសន្យាបញ្ចាំរវាងកូនក្តីខ្លួន និងសហចុងចម្លើយ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ត្រូវបានសហចុងចម្លើយបានចែងខរំលោភបំពានលក្ខខណ្ឌកិច្ចសន្យាបញ្ចាំយ៉ាងធ្ងន់ធ្ងរ លើលក្ខខណ្ឌទម្រង់នៃកិច្ចសន្យា និងផ្ទុយពីលក្ខខណ្ឌច្បាប់ ។ ផ្អែកតាមមាត្រា ៨១៦ នៃក្រមរដ្ឋប្បវេណី បានចែងអំពី "អត្ថន័យនៃសិទ្ធិលើការបញ្ចាំ", មាត្រា៨១៧ នៃក្រមរដ្ឋប្បវេណី បានចែងអំពី "ឧបាទេសកម្មលើវត្ថុ", មាត្រា៨១៨ នៃក្រមរដ្ឋប្បវេណី បានចែងអំពីការ"បង្កើតសិទ្ធិលើការបញ្ចាំ និងការប្រគល់វត្ថុជាចាំបាច់" និងផ្អែកតាមមាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី បានចែងអំពី "ការហាមឃាត់កិច្ចសន្យាបញ្ចាំផ្តាច់" បានបញ្ញត្តិត្រង់ថាបើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬច្បាប់ផ្សេងទៀតទេ អ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំមិនអាចព្រមព្រៀងឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំតាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។ តាមមាត្រានេះបានបញ្ជាក់ថា សហចុងចម្លើយបានបំពានកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យាបញ្ចាំ ហើយភាគីដើមចោទក៏បានធ្វើការស្នើសុំទូទាត់បំណុលជាច្រើនលើកជាច្រើនសារហើយ ថែមទាំងបានធ្វើការប្តឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរភូមិ អាជ្ញាធរឃុំ អាជ្ញាធរស្រុកថែមទៀតផង តែសហចុងចម្លើយនៅតែគេចវេសមិនព្រមអនុវត្តកាតព្វកិច្ចទទួលប្រាក់សង និងប្រាក់សំណងលើការបញ្ចាំ និងមិនព្រមប្រគល់អចលនវត្ថុ ឬដីស្រែដែលដាក់បញ្ចាំមកឱ្យសហដើមចោទវិញឡើយ ។ តាមមាត្រានេះ កូនក្តីរបស់ខ្លួនដែលជាសហដើមចោទ មានសិទ្ធិសុំរំលាយកិច្ចសន្យាបញ្ចាំនេះបាន ចំណែកមាត្រា៤១១ បានចែងអំពីអានុភាពនៃការរំលាយកិច្ចសន្យា កថាខណ្ឌទី២៖ ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬទាំងអស់ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀតវិញដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញដោយសារការរំលាយនោះ តាមមាត្រានេះភាគីសហចុងចម្លើយត្រូវមានករណីកិច្ចធ្វើការប្រគល់ ឬ សងត្រលប់មកវិញនូវដីជាទ្រព្យបញ្ចាំដែលខ្លួនបានទទួលពីសហដើមចោទដែលជាកូនក្តីរបស់ខ្លួន ដូចមានកំណត់តាមកិច្ចសន្យាបញ្ចាំដែលមានភ្ជាប់ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ និងបានធ្វើការបដិសេធជាច្រើនដង ដោយគិតចាប់ពីថ្ងៃដែលត្រូវបានទទួលប្រាក់ដើមសងពីសហដើមចោទ (មាត្រា៤០៧ នៃក្រមរដ្ឋប្បវេណី) តាំងពីក្នុងឆ្នាំ២០០៩ មកម្ល៉េះ រួមទាំងសំណងការខូចខាតផ្សេងៗទៀតដែលកើតចេញពីការមិនអនុវត្តកិច្ចសន្យា និងការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។ លើសពីនេះទៅទៀត ចំពោះការទាមទារសំណងជម្ងឺចិត្ត ឬសំណងការខូចខាត ដោយផ្អែកតាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី បានចែងអំពី "ទស្សនៈអំពីការខូចខាត" បានបញ្ញត្តិត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ ថា៖ តុលាការក៏អាចបង្គាប់ឱ្យ



Scanned with CamScanner

កូនបំណុលសង សំណងនៃការខូចខាតខាងផ្លូវចិត្តដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបានដែរ ។ ចំពោះចំនួនសំណងនៃការខូចខាតខាងផ្លូវចិត្ត តុលាការត្រូវសម្រេចដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ ។

សេចក្តីដូចបានជម្រាបជូនខាងលើ បានបញ្ជាក់យ៉ាងច្បាស់ថាសហដើមចោទដែលជាកូនក្តីរបស់ខ្លួន ពិតជាជនរងគ្រោះ ដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ច និងការបំពានកិច្ចសន្យាបញ្ចាំយ៉ាងធ្ងន់ធ្ងរពីសហចុងចម្លើយ ។ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិរបស់សហដើមចោទ សុំឱ្យតុលាការចេញសាលក្រមសម្រេចតាមការទាមទាររបស់សហដើមចោទដូចមាននៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤, ពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ និងពាក្យសុំកែតម្រូវពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ ។

**៤. អង្គហេតុដែលអះអាងដោយសហចុងចម្លើយ**

**សហចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា:** ពួកខ្លួនសុំរក្សាការអះអាងដូចមាននៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមការទាញហេតុផល ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ នៅដដែល លើសពីនេះសុំបន្ថែមថា: មេធាវីរបស់សហដើមចោទ ដែលបានលើកឡើងថាពួកខ្លួនបំពានកិច្ចសន្យាបញ្ចាំនោះមិនពិតទេ ហើយដីនោះពួកខ្លួនកាន់កាប់ និងអាស្រ័យផលយូរហើយតាំងពីឪពុកម្តាយខ្លួនបានទទួលមរណភាព ឪពុករបស់ខ្លួនឈ្មោះ [redacted] ផន និងម្តាយឈ្មោះ [redacted] រ៉េន ហើយកាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ពួកគាត់បានបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុដីមួយកន្លែងទំហំ ៧០ អា ស្ថិតនៅភូមិព្រៃសក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ជាមួយដើមចោទឈ្មោះ [redacted] ប៊ីក និងប្តីឈ្មោះ [redacted] យ៉ុង ( [redacted] យ៉ុង) ក្នុងតម្លៃប៉ុន្មាន ហើយព្រមព្រៀងគ្នាយ៉ាងណានោះខ្លួនមិនដឹងទេ ក្រោយមកនៅឆ្នាំ២០២៣ គណៈកម្មការសុរិយោដីបានចុះមកវាស់វែងធ្វើប្លង់ជាលក្ខណៈប្រព័ន្ធ ស្រាប់តែសហដើមចោទ និងមេភូមិបានទៅជំទាស់ក្នុងការវាស់វែង ដោយអះអាងថាដីនេះជាដីរបស់គាត់បញ្ចាំឱ្យឪពុកម្តាយខ្លួន មិនមែនលក់ទេ ហើយចាប់ពីពេលនោះមកក៏មានការប្តឹងផ្តល់គ្នារហូត តែការប្តឹងទាំងនោះមិនបានសម្រេចទេ ក្រោយមកទៀតនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ម្តាយខ្លួនឈ្មោះ [redacted] រ៉េន បានទទួលមរណភាព ក្រោយពីគាត់ទទួលមរណៈភាព ដីជំនាស់នេះ និងឯកសារទាំងអស់ស្ថិតនៅពួកខ្លួនជាអ្នកគ្រប់គ្រងរហូតដល់សព្វថ្ងៃ ។ ដូច្នេះក្នុងរឿងនេះសហដើមចោទប្តឹងទាមទារដូចមាននៅក្នុងកម្មវត្ថុខាងលើ ពួកខ្លួនមិនយល់ព្រមទេ មូលហេតុក្នុងកិច្ចសន្យាបញ្ចាំអចលនវត្ថុ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ សហដើមចោទឈ្មោះ [redacted] ប៊ីក និងប្តីឈ្មោះ [redacted] យ៉ុង ( [redacted] យ៉ុង) បានសន្យាថាការបញ្ចាំនេះមានរយៈពេល ០៣ ខែ ចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ រហូតដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ ពួកគាត់សុំបង្វិលប្រាក់ឱ្យវិញ បើមិនបានសងពួកគាត់ទាំងពីរនាក់ប្តីប្រពន្ធសុខចិត្តប្រគល់ដីស្រែនេះឱ្យមកឪពុកម្តាយខ្លួនឥតមានតវ៉ាឡើយ ហើយដីនេះរាល់ថ្ងៃពួកខ្លួនជាអ្នកកាន់កាប់ ។

**៥. ចំណុចគ្មានវិវាទ**

-"គ្មាន" ។

**៦. ចំណុចវិវាទ**

៦.១.តើសហដើមចោទមានមូលហេតុក្នុងការសុំរំលាយកិច្ចសន្យាបញ្ចាំចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ដែរឬទេ?

៦.២.តើសហដើមចោទមានមូលហេតុឱ្យសហចុងចម្លើយប្រគល់នូវដីស្រែទំហំ ៧០អា ដែលជាទ្រព្យធានាបញ្ចាំ ដែលមានទីតាំងដីស្ថិតនៅភូមិព្រៃសក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ដែរឬទេ ?

៦.៣.តើការទទួលស្គាល់ថាសហដើមចោទ ជាម្ចាស់កម្មសិទ្ធករលើដីស្រែទំហំ៧០អា មានទីតាំងស្ថិតនៅភូមិព្រៃសក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ មានលក្ខណៈត្រឹមត្រូវដែរឬទេ ?

៦.៤.បើការទាមទាររបស់សហដើមចោទមានលក្ខណៈត្រឹមត្រូវ តើសហចុងចម្លើយមានកាតព្វកិច្ចសងសំណងជម្ងឺចិត្តចំនួន **២០,០០០,០០០** (ម្ភៃលាន) រៀល ឬប៉ុន្មាន ?

៦.៥.សហដើមចោទមានករណីកិច្ចសងប្រាក់ត្រឡប់ទៅសហចុងចម្លើយនូវប្រាក់ដើមចំនួន **១,៦០០,០០០ (មួយលានប្រាំមួយសែន)** រៀល ឬប៉ុន្មាន ?

៦.៦.តើសហដើមចោទមានហេតុផលចាំបាច់ ក្នុងការស្នើសុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្នដែរឬទេ?



Scanned with CamScanner

## ខ. ការពិនិត្យភស្តុតាង

### ១. ភស្តុតាងជាឯកសាររបស់សហដើមចោទ

១.១. របាយការណ៍ស្តីពីករណីវិវាទការបញ្ចាំដីស្រែមួយកន្លែង ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ ។

១.២. ការបញ្ជូនសំណុំរឿងទំនាស់បញ្ចាំដីធ្លីមកថ្នាក់ស្រុកដើម្បីដោះស្រាយ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ។

១.៣. កំណត់ហេតុនៅភូមិព្រៃសក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ។

១.៤. កិច្ចសន្យាបញ្ចាំអចលនវត្ថុ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ។

១.៥. កំណត់ហេតុស្តីពីការសម្រុះសម្រួល ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ។

១.៦. កំណត់ហេតុស្តីពីការសម្រុះសម្រួល ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ។

១.៧. កំណត់ហេតុស្តីពីការសម្រុះសម្រួល ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ។

១.៨. ពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ។

១.៩. ពាក្យសុំកែតម្រូវពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ ។

១.១០. លិខិតស្នើសុំបញ្ជាក់ប្រវត្តិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ។

១.១១. លិខិតបញ្ជាក់ដីធ្លី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ។

១.១២.សេចក្តីថ្លែងការណ៍អំពីលទ្ធផល នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤។

១.១៣.ពាក្យស្នើសុំបញ្ចូលសាក្សី ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ។

### ២. ភស្តុតាងជាឯកសាររបស់សហចុងចោទ

២.១. ពាក្យសុំបញ្ចូលភស្តុតាង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ ។

២.២. លិខិតបញ្ជាក់ប្រវត្តិដីធ្លី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ ។

២.៣. កិច្ចសន្យាបញ្ចាំអចលនវត្ថុ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ។

### ៣. ការសាកសួរសាក្សី

៣.១.សាក្សីឈ្មោះ [redacted] ហ៊ាម ភេទប្រុស អាយុ ៥០ឆ្នាំ មុខរបរ មេភូមិព្រៃសក្រោម បានឆ្លើយថា៖ កាលពីឆ្នាំ២០០៥ មេភូមិចាស់ឈ្មោះ [redacted] ង៉ូវ ជាមេភូមិដល់ឆ្នាំ២០១៣ មេភូមិចាស់គាត់ចាស់ជរា ខ្លួនក៏ឡើងជាមេភូមិជំនួសគាត់វិញ ។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ឈ្មោះ [redacted] ប៊ុក និងប្តីរបស់គាត់ឈ្មោះ [redacted] យ៉ុង ([redacted] យ៉ុង) យកដីទៅបញ្ចាំឱ្យឈ្មោះ [redacted] ថន និងប្រពន្ធឈ្មោះ [redacted] រ៉ីន ដែលជាឪពុកម្តាយរបស់ឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] ភ័ណ្ឌ ក្នុងតម្លៃប៉ុន្មាន ហើយបានធ្វើកិច្ចសន្យាបញ្ចាំយ៉ាងណានោះខ្លួនមិនដឹងទេ តែខ្លួនដឹងថាដីដែលមានទំនាស់នេះពីដើមជាដីរបស់ឈ្មោះ [redacted] ថន និងប្រពន្ធ ឈ្មោះ [redacted] រ៉ីន ហើយក្រោយពេលដែលខ្លួនឡើងធ្វើមេភូមិនៅក្នុងឆ្នាំ២០១៦ ឬឆ្នាំ២០១៧ មានឈ្មោះ [redacted] ប៊ុក និងប្តីរបស់គាត់ឈ្មោះ [redacted] យ៉ុង ([redacted] យ៉ុង) ទៅប្តឹងខ្លួនពីគាត់សុំលោះដីពីឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] ភ័ណ្ឌ តែខ្លួនជាមេភូមិក្រោយមិនអាចធ្វើបានទេ ខ្លួនក៏បានឱ្យគាត់ទៅប្តឹងនៅសាលាឃុំទៅ ក្រោយមកទៀតគ្រង់ថាគាត់ប្តឹងគ្នាយ៉ាងណានោះខ្លួនមិនដឹងទេ តែខ្លួនដឹងថាដីនេះក្រោយពីឆ្នាំ១៩៧៩ មក គឺជាដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] ប៊ុក និងប្តីរបស់គាត់ ឈ្មោះ [redacted] យ៉ុង ([redacted] យ៉ុង) ជាអ្នកកាន់កាប់ និងអាស្រ័យផល ហើយប្រជាពលរដ្ឋនៅក្នុងភូមិអ្នកណាក៏ដឹងដែរ តែក្រោយពីដាក់បញ្ចាំរួច គឺដីនេះស្ថិតនៅលើឈ្មោះ [redacted] ថន និងប្រពន្ធឈ្មោះ [redacted] រ៉ីន ជាអ្នកកាប់កាប់ និងអាស្រ័យផល ហើយក្រោយពីឈ្មោះ [redacted] ថន និងប្រពន្ធឈ្មោះ [redacted] រ៉ីន បានទទួលមរណភាពអស់ទៅឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] ភ័ណ្ឌ ដែលត្រូវជាកូនរបស់គាត់កាន់កាប់ និងអាស្រ័យផលរហូតមកដល់សព្វថ្ងៃនេះ ។

៣.២.សាក្សីឈ្មោះ [redacted] អ៊ុយ ភេទប្រុស អាយុ ៧១ឆ្នាំ មុខរបរ មេឃុំខ្វាវ បានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ២០០៥ ឈ្មោះ [redacted] ប៊ុក និងប្តីរបស់គាត់ឈ្មោះ [redacted] យ៉ុង ([redacted] យ៉ុង) យកដីទៅបញ្ចាំឱ្យឈ្មោះ [redacted] ថន និងប្រពន្ធឈ្មោះ [redacted] រ៉ីន ក្នុងតម្លៃប៉ុន្មាន ហើយសន្យាជាមួយគ្នាយ៉ាងណានោះខ្លួនមិនដឹងទេ ដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ឈ្មោះ [redacted] ថន

ឆ្នាំ២០០១ ដែលត្រូវបានវិសោធនកម្មលុបដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ក៏បានចែងថា៖ "ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករ នៃទ្រព្យជាប់កិច្ចសន្យាបញ្ចាំបានឡើយ" និងផ្អែកតាមបញ្ញត្តិមាត្រា **៨២៧** នៃក្រមរដ្ឋប្បវេណី ក៏បានចែងអំពីការហាមកិច្ចសន្យាបញ្ចាំផ្តាច់ផងដែរ ដូច្នេះសហចុងចម្លើយមិនអាចក្លាយជាកម្មសិទ្ធិករលើទ្រព្យជាប់កិច្ចសន្យាបញ្ចាំបានឡើយ ទោះបីមានចែងកិច្ចសន្យាប្រគល់ដីស្រែក៏ដោយ ។

៥.ផ្អែកតាមលិខិតបញ្ជាក់ដីធ្លី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ចេញដោយមេឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ដែលជាភស្តុតាងរបស់សហដើមចោទ និងផ្អែកតាមលិខិតបញ្ជាក់ប្រវត្តិដីធ្លី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ ចេញដោយមេឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ដែលជាភស្តុតាងរបស់សហចុងចម្លើយ បានបញ្ជាក់ថា៖ ដីស្រែទំហំ៧០អា មានព្រំប្រទល់ខាងកើតទល់នឹងឈ្មោះ [redacted] **ថន**, ខាងលិចទល់នឹងឈ្មោះ [redacted] **ហ៊ុន**, ខាងជើងទល់នឹងឈ្មោះ [redacted] **សារី** និងខាងត្បូងទល់នឹងឈ្មោះ [redacted] **សឿង** ស្ថិតនៅភូមិព្រៃសក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ពិតជាបានកាន់កាប់ និងអាស្រ័យផលដោយឪពុកម្តាយរបស់សហដើមចោទចាប់ពីឆ្នាំ១៩៧៩ ពិតប្រាកដមែន និងក្រោយពីការដាក់បញ្ចាំត្រូវបានកាន់កាប់ និងអាស្រ័យផលដោយឪពុកម្តាយរបស់សហចុងចម្លើយ និងបន្តកាន់កាប់ និងអាស្រ័យផលដោយសហចុងចម្លើយមកដល់បច្ចុប្បន្ន ពិតប្រាកដមែន ដែលការបញ្ជាក់នេះមានភាពស៊ីសង្វាក់ជាមួយការបំភ្លឺរបស់សាក្សីដែលបានបំភ្លឺថា៖ ដីទំនាស់នេះពីមុនមកអ្នកណាបញ្ចាំឱ្យអ្នកណានោះ ខ្លួនមិនដឹងទេ តែក្រោយមកខ្លួនឃើញតែឈ្មោះ [redacted] **ភាព** និងឈ្មោះ [redacted] **ភ័ណ្ឌ** ដែលត្រូវជាកូនជាអ្នកកាន់កាប់ និងអាស្រ័យផលរហូតដល់សព្វថ្ងៃ ក្រៅពីនេះខ្លួនមិនដឹងទេ ។ តុលាការយល់ឃើញថា៖ ការកាន់កាប់ និងអាស្រ័យផលដោយសហចុងចម្លើយចាប់តាំងពីការដាក់ទ្រព្យបញ្ចាំមក មិនមានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌបញ្ញត្តិមាត្រា **១៦២** នៃក្រមរដ្ឋប្បវេណីឡើយ ក្នុងការធ្វើលទ្ធកម្មកម្មសិទ្ធិ លើទ្រព្យបញ្ចាំខាងលើ ព្រោះការកាន់កាប់នោះមិនដោយសន្តិវិធី និងមានកំហុស គឺសហចុងចម្លើយកាន់កាប់ និងអាស្រ័យផលដោយមានជាប់កិច្ចសន្យាបញ្ចាំអចលនវត្ថុលេខ: **១០៦** ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ រវាងឈ្មោះ [redacted] **ប៊ុក** និងប្តីឈ្មោះ [redacted] **យ៉ុង** និងឈ្មោះ [redacted] **ថន** និងប្រពន្ធឈ្មោះ [redacted] **ប៊ីន** មិនមែនជាកាន់កាប់ និងអាស្រ័យផលដោយមានកិច្ចសន្យាលក់ផ្តាច់ឡើយ ។

៦.សហដើមចោទបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាក្រៅតុលាការរួចហើយ ហើយសហចុងចម្លើយក៏បានទទួលដំណឹងអំពីការរំលាយកិច្ចសន្យានោះហើយដែរ តាមបញ្ញត្តិមាត្រា **៤០៩** នៃក្រមរដ្ឋប្បវេណី ហើយអានុភាពការរំលាយកិច្ចសន្យានាំឱ្យភាគីទាំងសងខាងត្រូវធ្វើបដិទានឱ្យគ្នាទៅវិញទៅមក ដោយសហដើមចោទមានករណីកិច្ចសងប្រាក់ត្រឡប់ទៅសហចុងចម្លើយចំនួន **១,៦០០,០០០ (មួយលានហុកសិបម៉ឺន)** រៀល និងសហចុងចម្លើយមានករណីកិច្ចប្រគល់បង្វិលអចលនវត្ថុដែលបានទទួលបញ្ចាំទៅឱ្យសហដើមចោទវិញ តាមបញ្ញត្តិមាត្រា **៤១១** នៃក្រមរដ្ឋវេណី ដូច្នេះតុលាការមិនចាំបាច់រំលាយកិច្ចសន្យាបញ្ចាំអចលនវត្ថុ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ទៀតឡើយ ដូច្នេះគប្បីតុលាការសម្រេចច្រានចោលការទាមទារត្រង់ចំណុចនេះ ។

**៧**.សហដើមចោទទាមទារឱ្យតុលាការទទួលស្គាល់ថាសហដើមចោទ ជាម្ចាស់កម្មសិទ្ធករលើដីស្រែទំហំ៧០អា មានទីតាំងស្ថិតនៅភូមិព្រៃសក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ តុលាការយល់ឃើញថាមិនមានភាពចាំបាច់ក្នុងការបញ្ជាក់ទទួលស្គាល់ឡើយ ដូច្នេះគប្បីតុលាការសម្រេចច្រានចោលការទាមទារត្រង់ចំណុចនេះ ។

**៨**.សហដើមចោទទាមទារសំណងជម្ងឺចិត្តចំនួន **២០.០០០.០០០៛** (**ម្ភៃលាន**) រៀល ដោយសហដើមចោទមិនមានភស្តុតាងណាមួយបញ្ជាក់អំពីទំហំការខូចខាតមកតុលាការឡើយ ដូច្នេះគប្បីតុលាការសម្រេចច្រានចោលការទាមទារត្រង់ចំណុចនេះ ។

៩.សហដើមចោទស្នើសុំអនុវត្តជាបណ្តោះអាសន្នលើសាលក្រម តុលាការយល់ឃើញថា: មិនមានភាពចាំចាច់ណាក្នុងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នលើសាលក្រម តាមបញ្ញត្តិមាត្រា **១៩៦** នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ ដូច្នេះគប្បីតុលាការសម្រេចច្រានចោលការទាមទារត្រង់ចំណុចនេះ យោងតាមសេចក្តីណែនាំលេខ: **១១៤/០៨ តកក** ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៨របស់តុលាការកំពូល ។

១០. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ តាមបញ្ញត្តិមាត្រា **៦៤** នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

**<u>សេចក្ដីសម្រេចបញ្ចប់</u>**

១.បង្គាប់ឱ្យសហចុងចម្លើយបង្វិលប្រគល់នូវដីស្រែទំហំ៧០អា មានទីតាំងស្ថិតនៅភូមិព្រៃសក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ដែលជាទ្រព្យបញ្ចាំឱ្យទៅសហដើមចោទវិញ ។

២.បង្គាប់ឱ្យសហដើមចោទសងប្រាក់ចំនួន **១,៦០០,០០០ (មួយលានហុកសិបម៉ឺន)** រៀល ទៅសហចុងចម្លើយវិញ ។

៣.ច្រានចោលការទាមទារត្រង់ចំណុចទី**១**,ទី**៣**, ទី**៤** និងទី**៧** នៃពាក្យសុំកែតម្រូវពាក្យបណ្ដឹងបន្ថែម ។

៤.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

សាលក្រមនេះបានបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ **នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤** និងប្រកាសសាលក្រមជាសាធារណៈ **នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤** ចំពោះមុខសហដើមចោទ និងសហចុងចម្លើយ ។

*ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

ថ្ងៃអង្គារ ៨ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ធ្វើនៅតាកែវ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ៨ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ធ្វើនៅតាកែវ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ធ្វើនៅតាកែវ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤

**ចៅក្រម**

[redacted]



Scanned with CamScanner